អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៤

# សេចក្តីប្រកាសព័ត៌មាន

អង្គជំនុំជម្រះតុលាការកំពូលនៃ អ.វ.ត.ក. ប្រគល់ឯកសារត្រលប់មក
សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

មជ្ឈមណ្ឌលធនធាន អ.វ.ត.ក. - អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៤ បានប្រគល់ឯកសារត្រលប់មកសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងវិញ ដូចនៅពេលដែលបានផ្តល់ដោយសាស្ត្រាចារ្យ Walter Heynowski កាលពីដំបូង។

ឯកឧត្តម ក្រាញ់ តូនី ប្រធានរដ្ឋបាលស្តីទីនៃ អ.វ.ត.ក. មានប្រសាសន៍ថា៖ «អ.វ.ត.ក.សូមថ្លែងអំណរគុណចំពោះសាស្ត្រាចារ្យ Walter Heynowski និង សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលបានផ្តល់ឱកាសដល់ អ.វ.ត.ក. ដើម្បីប្រើប្រាស់ឯកសារទាំងនេះ ដែលបានរួមចំណែកដ៏មានតម្លៃចំពោះភស្តុតាងក្នុងសំណុំរឿង ០០២/០២»។

ឯកឧត្តម ក្រាញ់ តូនី មានប្រសាសន៍បន្តថា៖ «ជាផ្នែកនៃអាណត្តិរបស់អ.វ.ត.ក. ក្នុងដំណាក់កាលសេសសល់ យើងកំពុងបន្តផ្តល់អាទិភាពដល់សកម្មភាពដែលជួយក្នុងការផ្សព្វផ្សាយព័ត៌មានដើម្បីលើកកម្ពស់កេរដំណែលរបស់អ.វ.ត.ក.។ ដោយមើលឃើញពីការប្តេជ្ញាចិត្តនេះ យើងបានស្កេនឯកសារទាំងនេះ ដើម្បីអាចចូលប្រើជាឌីជីថលដោយអ្នកជំនាញ និង សាធារណជនទូទៅ។ យើងសង្ឃឹមថា ឯកសារទាំងនេះ នឹងបន្តផ្តល់អត្ថប្រយោជន៍ដល់ការស្រាវជ្រាវ និង សកម្មភាពយុត្តិធម៌អន្តរកាលដែលបង្កើនការយល់ដឹងអំពីរបបខ្មែរក្រហម និង ធានាបាននូវសន្តិភាពប្រកបដោយនិរន្តរភាព»។

លោក ហង្ស និស្ស័យ ប្រធានសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ អ.វ.ត.ក. សម្រាប់ការប្រគល់ឯកសារត្រលប់មកសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដោយធានាថា ឯកសារទាំងនេះនឹងត្រូវរក្សាទុកយ៉ាងត្រឹមត្រូវក្នុងគោលបំណងសិក្សា និង ស្រាវជ្រាវ។

ឯកសារខាងក្រោមនេះ គឺត្រូវបានប្រគល់ត្រលប់មកសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងវិញ៖
(១) សៀវភៅកត់ត្រា ដែលមានជាតុសរសេរដោយដៃ; និង
(២) រូបថត ឬ សន្លឹកទំនាក់ទំនងនៃអ្វីដែលមើលទៅដូចជាអ្នកទោស។

ឯកសារទាំងនេះពិតជាមានសារៈសំខាន់ក្នុងដំណើរការស៊ើបអង្កេត។ ឯកសារទាំងនេះ បានបង្ហាញពីទិដ្ឋភាពសំខាន់ៗនៃប្រវត្តិសាស្ត្រនៃសម័យខ្មែរក្រហម ដែលមិនមាននៅក្នុងឯកសារផ្សេងទៀត។ ព័ត៌មានតែមួយគត់ ត្រឹមត្រូវ និងទាន់ពេលវេលាមានតម្លៃខ្ពស់ក្នុងអំឡុងពេលដំណើរការផ្លូវច្បាប់ ហើយមានសារៈសំខាន់សម្រាប់ការបង្កើតកំណត់ត្រាប្រវត្តិសាស្ត្រត្រឹមត្រូវ។

###

**សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖**

**លោក គុណ ចិន្តា**
មន្ត្រីទទួលបន្ទុកផ្នែកព័ត៌មាន ផ្នែកកិច្ចការសាធារណៈ
លេខទូរស័ព្ទទំនាក់ទំនង៖ +៨៥៥ (០)១២ ៣៣៦ ០៩៧
អ៊ីម៉ែល៖ kun.chenda@eccc.gov.kh